# សង្ខេបប្រតិបត្តិ

༺໑༻

របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានរួមមានជប់ជំពូកដែលផ្តល់ការពិពណ៌នាយ៉ាងទូលំទូលាយពីរបៀបដំណើរការនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថានសំរាប់គំរោងរោងចក្រវារីអគ្គិសនីសេសានក្រោមទី២ ដែលបានសិក្សា និងរកឃើញនូវហេតុប៉ះពាល់ទៅលើបរិស្ថាន និងសង្គមរបស់គំរោង រួមជាមួយនឹងការលើកអនុសាសន៍នានាសំរាប់វិធានការណ៍បន្ធូរបន្ថយ ដែលគំរោងត្រូវអនុវត្តតាមដំណាក់កាលនិមួយៗ។ ទំរង់នៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ធ្វើឡើងស្របទៅតាមគោលការណ៍ណែនាំរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និង ពង្រាងគោលការណ៍ណែនាំស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថានរៀបចំដោយក្រសួងបរិស្ថាន។

## ១. សេចក្តីផ្តើម

គំរោងរោងចក្រវារីអគ្គិសនីសេសានក្រោមទី២ (Lower Se San 2 HPP) ជាគំរោងខ្នាតធំដែលតំរូវអោយធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន (EIA) ក្រោមច្បាប់នានារបស់កម្ពុជា។ EIA ពិនិត្យមើលពីសក្តានុពលនៃហេតុប៉ះពាល់ទៅលើបរិស្ថាន និងសង្គម ហើយរៀបចំវិធានការណ៍បន្ធូរបន្ថយចំពោះហេតុប៉ះពាល់ជាអវិជ្ជមាននិមួយៗក្នុងកំឡុងពេលមុនសាងសង់ ពេលសាងសង់ និងដំណាក់កាលប្រតិបត្តិ ដើម្បីកាត់បន្ថយហេតុប៉ះពាល់អោយនៅតិចបំផុតតាមដែលអាចធ្វើទៅបាន។

EIA ត្រូវបានរៀបចំឡើងដោយក្រុមហ៊ុនឃីខនសល់ធេនខេមបូឌា (KCC) នៅក្រោមកិច្ចសន្យាពីក្រុមហ៊ុនទី១ ផាវ័រ អិនជិនញ្ញើរីង ខនសាល់ធីង (PECC1) កំពុងធ្វើការសិក្សាពីសមិទ្ធិលទ្ធភាពទាំងមូលសំរាប់គំរោង នៃអគ្គិសនីវៀតណាម(EVN) ដែលជាក្រុមហ៊ុនប្រទេសវៀតណាម ធ្វើការវិនិយោគលើគំរោងសេសានក្រោមទី២នេះ។ ការចុះអនុសារណៈយោគយល់ MOU រវាង EVN និង ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល (MIME) បានចុះហត្ថលេខានៅក្នុងខែ មិថុនា ២០០៧ អោយ EVN ដើម្បីធ្វើការសិក្សាពីសមិទ្ធិលទ្ធភាព។ របាយការណ៍ EIA នេះបានរៀបចំឡើង ចាប់ពីខែមករា ដល់ ខែកក្កដា ២០០៨។

គោលបំណងគន្លឹះរបស់គំរោងរោងចក្រវារីអគ្គិសនីសេសានក្រោមទី២ គឺដើម្បីបំពេញបង្គ្រប់តំរូវការថាមពលរយៈពេលមធ្យម និងវែងរបស់ព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាការនាំចេញថាមពលមួយចំនួនដែលលើសពីតំរូវការ។ គំរោងនេះឆ្លើយតបផងដែរ ទៅនឹងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលអណត្តិទីបី ដែលទាក់ទងទៅនឹងការអភិវឌ្ឍន៍វិស័យថាមពលអោយគ្រប់គ្រាន់ទៅតាមតំរូវការសំរាប់ថាមពលអគ្គិសនីដែលមានតំលៃទាប។ គោលបំណងសំខាន់ផ្សេងទៀតគឺដើម្បីធានាបានថាការបង្កើតថាមពល និងផលប៉ះពាល់ជាវិជ្ជមានរបស់វាដល់ប្រទេសជាតិ គឺត្រូវបានថ្លឹងថ្លែងឡើងយ៉ាងប្រុងប្រយ័ត្នទៅនឹងហេតុប៉ះពាល់អវិជ្ជមានដល់បរិស្ថាន និងសង្គម ដែលវានឹងបង្កឡើងជាពិសេសនៅលើតំបន់ខាងក្រោម និង ខាងលើខ្សែទឹករបស់តំបន់គំរោង។

Draft

ពត៌មានដែលប្រមូលបានសំរាប់ការរៀបចំរបាយការណ៍ EIA គឺបានពីប្រភពទិន្នន័យសិក្សាជាក់ស្តែង និង ប្រភពទិន្នន័យមានស្រាប់ឬរបាយការណ៍សិក្សាចាស់ៗ ដែលរួមមាន សត្វព្រៃ ត្រី និង ការស្ទង់មតិទៅលើសង្គម ការសម្ភាសន៍/ការប្រជុំជាមួយសហគមន៍ និងការសំយោគឯកសារ ជាពិសេសរបាយការណ៍ដែលមានស្រាប់ទៅលើ សត្វព្រៃ ត្រី និង ការស្ទង់មតិផ្នែកសង្គមដែលមានពីមុនមកនៅក្នុងតំបន់គំរោង។

## ២. ក្របខ័ណ្ឌច្បាប់ និង និយតកម្មផ្សេងៗ

រោងចក្រវារីអគ្គិសនីដែលបានស្នើឡើងគឺស្ថិតនៅក្រោមការត្រួតពិនិត្យដោយផ្ទាល់ពីអាជ្ញាធរអគ្គិសនីកម្ពុជា និង ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល។ ភ្នាក់ងារជាច្រើនផ្សេងទៀតមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងគំរោងសំណើនេះដោយរាប់បញ្ចូលទាំងក្រសួងបរិស្ថាន (MoE) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (MAFF) ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (MEF) ក្រសួងគ្រប់គ្រងដែនដី នគររូបនីយកម្ម និង សំណង់ (MLMUPC) និង ក្រសួងធនធានទឹក និង ឧតុនិយម (MoWRAM)។

ច្បាប់ និង គោលការណ៍ណែនាំដែលពាក់ព័ន្ធសំរាប់គំរោងនេះរួមមាន៖

- *រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា (១៩៩៣)*
- *ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ (១៩៩៦)*
- *ព្រះរាជក្រឹតស្តីពីតំបន់ការពារធម្មជាតិ (១៩៩៣)*
- *អនុក្រិតស្តីពី ដំណើរការវាយតំលៃផលប៉ះពាល់បរិស្ថាន (១៩៩៩)*
- *អនុក្រិតស្តីពី ការត្រួតពិនិត្យការបំពុលទឹក (១៩៩៩)*
- *អនុក្រិតស្តីពី ការគ្រប់គ្រងកាកសំណល់រឹង (១៩៩៩)*
- *ច្បាប់ដីធ្លី (២០០១)*
- *ច្បាប់ព្រៃឈើ (២០០២)*
- *ច្បាប់គ្រប់គ្រងធនធានទឹក (២០០៧)*
- *គោលនយោបាយធនធានទឹកថ្នាក់ជាតិ (២០០៤)*

## ៣. ការពណ៌នាពីគំរោង

គំរោងរោងចក្រវារីអគ្គិសនីសេសានក្រោមទី២ ជាគំរោងថាមពលវារីអគ្គិសនីដែលមានទីតាំងនៅលើទន្លេសេសាន នៅក្នុងឃុំចំនួនបួនក្នុងស្រុកសេសាន (ឃុំភ្លុក ស្រែគរ តាឡាត់ និង ឃុំក្បាលរមាស) ខេត្តស្ទឹងត្រែង

Draft

ប្រទេសកម្ពុជា និងមានចំងាយប្រហែល ១.៥គម ខាងក្រោមចំនុចប្រសព្វទន្លេសេសាន និងទន្លេស្រែពក និងមានចំងាយប្រហែល ២៥ គម នៃខ្សែទឹកខាងលើនៃទីរួមខេត្តស្ទឹងត្រែង ។

គំរោងនឹងមានតំឡើងនូវកាប៉ាស៊ីតេ ៤០០មេហ្គាវ៉ាត់ ដើម្បីផ្គត់ផ្គង់អគ្គិសនីដល់ខេត្តដែលនៅជុំវិញ នឹងធ្វើការនាំចេញទៅកាន់ប្រទេសវៀតណាម ។ វានឹងទាក់ទងផងដែរក្នុងដំណាក់កាលសាងសង់ដែលមានរយៈពេល ៤ ឆ្នាំ និងប្រើប្រាស់កំលាំងពលកម្មប្រហែល ៣០០០ នាក់ ។ គំរោងនេះជាគំរោងប្រភេទ BOT **(សាងសង់ ប្រតិបត្តិការ និងផ្ទេរ)** ហើយដែលមាន**តំលៃវិនិយោគសរុប ៨១៦,២៣ លានដុល្លាអាមេរិក** ។

សមាសធាតុសំខាន់ៗ របស់ទំនប់មានដូចជា:

- ទំនប់មេៈ ទំនប់ចាក់ដីស្មើសាច់ដែលមានប្រវែងសរុប ៨គម កំពស់ខ្នងទំនប់ ៨៣ម លើនីវ៉ូទឹកសមុទ្រ ឬ ប្រហែល ៤០ម ខ្ពស់ជាងបាតទន្លេ និងមានទទឹងខ្នងលើ ៨ម ។
- អាគារផលិតថាមពលនៅលើច្រាំងខាងឆ្វេង បំពាក់ដោយ ទួរប៊ីន ៥ គ្រឿង ដែលមួយគ្រឿងៗមានកាប៉ាស៊ីតេ ៨០ មេហ្គាវ៉ាត់ ។
- សំណង់ទ្វារទឹកបង្ហៀររាងចតុកោណដែលមានវិមាត្រ ១៥ម x ១៦ម ហើយមាន ១២ប្រលោះទ្វារ អនុលោមទៅតាមការវិភាគរបបជលសាស្ត្ររបស់ចារទឹកទន្លេ ។
- អាងស្តុកទឹកដែលមានកាប៉ាស៊ីតេស្តុកចំណុះ ១.៧៥ ពាន់លានម៉ែត្រគូប និង ផ្ទៃលិចទឹក ៣៣៥ គម² នៅពេលដែលនីវ៉ូទឹកក្នុងអាងស្តុកឡើងដល់កំពស់ ៧៥ម (តំរូវអោយមានការតាំងទីលំនៅសារជាថ្មី ១០៥២ គ្រួសារនៅ ក្នុងតំបន់តាំងទីលំនៅសារជាថ្មីចំនួន ៦ កន្លែង) ។
- សមាសធាតុជំនួយផ្សេងៗជាច្រើនទៀតរួមមាន ច្រកទឹកចូល សន្ទះបិតបើក ទីលានបំលែងភ្លើង (switch yard) 220Kv, ប្រឡាយបញ្ចេញពីអាគារផលិតថាមពល (tailrace) អាគាររដ្ឋបាល និងអាគារប្រតិបត្តិការ ។

គំរោងមានដំណាក់កាលសំខាន់ៗបីៈ ដំណាក់កាលរៀបចំបូង (ដំណាក់កាលបច្ចុប្បន្ន ចាប់ពីឆ្នាំ ២០០៨-២០០៩) ដំណាក់កាលសាងសង់ (ចាប់ពីឆ្នាំ ២០១០-២០១៤) និង ដំណាក់កាលប្រតិបត្តិ (ចាប់ពីឆ្នាំ ២០១៥ ឡើងទៅ) ។ គេរំពឹងថាទំនប់មានអាយុដំណើរការបាន ១០០ ឆ្នាំ ។

គំរោងនេះត្រូវការជាចាំបាច់ដើម្បីឆ្លើយតបទៅនឹងតំរូវការអគ្គិសនីបច្ចុប្បន្ន និងអនាគត របស់ប្រទេស ដែលគេទស្សន៍ទាយថានិងកើនឡើងនៅក្នុងឆ្នាំខាងមុខ ហើយដើម្បីភ្ជាប់ប្រព័ន្ធផ្គត់ផ្គង់ផ្សេងទៀតនៅក្នុងប្រទេស និង ក្នុងតំបន់ទាំងមូល ។

## ៤_ បរិស្ថានដើម

### *ក) បរិស្ថានរូបសាស្ត្រ*

Draft

លក្ខណៈជាទេសភាពនៅក្នុង និងនៅជុំវិញតំបន់គំរោង គឺជាដីដែលមានចំណោតបន្តិចម្តងៗឡើងទៅរកតំបន់ខ្ពង់រាបនៅក្នុងខេត្តរតនគីរី ដែលរួមមានជាចំបងនូវព្រៃឈើ និងទន្លេ ប៉ុន្តែក៏មានដីមួយចំនួន ជាដីលំនៅដ្ឋាន និងដីកសិកម្មផងដែរ។ បាតទន្លេសេសាននៅទីតាំងទំនប់មានរយៈកំពស់ជាមធ្យម ៤០ម ធៀបទៅនឹងនីវ៉ូទឹកសមុទ្រ ហើយបាតទន្លេនៅតំបន់អាងស្តុកទឹកផ្នែកខាងលើមានរយៈកំពស់ប្រហែល ៦០ម ធៀបទៅនឹងនីវ៉ូទឹកសមុទ្រ ។ អាកាសធាតុមានលក្ខណៈជាអាកាសធាតុម៉ូសុងដែលមានរដូវប្រាំង និងរដូវវស្សា ដែលមានរយៈពេល ៦ខែ ក្នុងមួយរដូវ ។ រដូវប្រាំងចាប់ពី ខែវិច្ឆកា ដល់ខែមេសា និងរដូវវស្សា ពីខែឧសភា ដល់ខែតុលា ។ ជាទូទៅគុណភាពខ្យល់មានលក្ខណៈល្អប្រសើរ លើកលែងតែនៅតំបន់ជិតថ្នល់មានភាពហុយនៅក្នុងរដូវប្រាំង។

ទន្លេសេសាន និង ទន្លេស្រែពកដែលហូរកាត់តាមតំបន់គំរោង គឺជាដៃសំខាន់របស់ទន្លេមេគង្គ ហើយទន្លេទាំងពីរមានប្រភពដើមនៅលើខ្ពង់រាបភាគកណ្តាលរបស់ប្រទេសវៀតណាម។ ទន្លេសេសានមានប្រវែងសរុប ៤៦២ គ.ម (ដែលប្រវែង ២៥២ គ.ម ស្ថិតនៅក្នុងប្រទេសកម្ពុជា) និង មានផ្ទៃរងទឹកភ្លៀង ១៨.៨៨៨ គ.ម$^{២}$ ហើយទន្លេស្រែពកមានប្រវែងសរុប ៥២០ គ.ម (ដែលប្រវែង ២៤៥ គ.ម ស្ថិតនៅក្នុងប្រទេសកម្ពុជា) និងមានផ្ទៃរងទឹកភ្លៀង ៣០.៩៤២ គ.ម$^{២}$។ ធារទឹកមធ្យមរបស់ទន្លេសេសាន និង ទន្លេស្រែពក នៅក្បែរតំបន់គំរោងគឺ ៦៣៣ ម$^{៣}$/វិនាទី និង ៦៦៧ ម$^{៣}$/វិនាទី។ គុណភាពទឹករបស់ទន្លេនៅក្នុង និងនៅជុំវិញតំបន់គំរោងមានលក្ខណៈធម្មតា ហើយនីវ៉ូទឹកក្រោមដីស្ថិតនៅប្រហែល ៨ម នៅរដូវប្រាំង។ កំរិតកករនៅក្នុងទន្លេទាំងពីរមានកំរិតខ្ពស់។ ស្នាមប្រេះភូគព្ភសាស្ត្រមួយចំនួនមានវត្តមាននៅក្បែរតំបន់គំរោង ហើយនៅឆ្នាំ ១៩៧៨ រញ្ជួយដីមួយដែលបានកត់ត្រាមានកំរិតរង្វាស់ ៥,២ Richter បានកើតឡើងនៅក្នុងតំបន់គំរោង។

Draft

### *b) ធនធានអេកូឡូស៊ី*

បរិស្ថានអេកូឡូស៊ីដែលមាននៅក្នុង និងនៅជុំវិញតំបន់គំរោង រួមមានតំបន់មួយចំនួនដែលទាក់ទងទៅនឹងព្រៃឈើទាំងមូល (ជាធម្មតាពពួកព្រៃ deciduous dipterocarp) និង ពពួកសត្វមានជំរកនៅក្នុងទឹកទន្លេ ដែលអាចមានផ្ទុកនូវពពួកពូជសត្វកំរ និង សត្វកំពុងរងគ្រោះថ្នាក់ (ដូចជា ខ្ទីង ទន្សោង រមាំង និង បក្សីមួយចំនួនទៀត) ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏នៅមានតំបន់ដែលរងការខូចខាតមួយចំនួនទៀតផងដែរ ដែលកើតមានពីការកាប់ឈើពីអតីតកាល និង ផលប៉ះពាល់ដោយការតាំងទីលំនៅ និងការបរបាញ់ ។ ការកាប់ឈើដោយជ្រើសរើស និងការប្រមូលអនុផលព្រៃឈើនៅតែកើតឡើងនៅក្នុង និងនៅជុំវិញតំបន់គំរោង។ មានប្រហែល ៣០.០០០ ហតនៃតំបន់គំរោង (រាប់ទាំងតំបន់តាំងទីលំនៅដែលបានស្នើឡើង) ដែលបច្ចុប្បន្នជាដីព្រៃឈើ។

តំបន់គំរោង លាតសន្ធឹងនៅក្នុងតំបន់អេកូឡូស៊ី ព្រៃស្ងួតទន្លេមេគង្គក្រោម (LMDFE) ជាតំបន់មួយទទួលស្គាល់ជាអន្តរជាតិ ថាជាតំបន់មានសារៈសំខាន់ជាសាកលសំរាប់ការអភិរក្សជីវចំរុះ ហើយក៏ស្ថិតនៅក្នុងតំបន់ដែលមានបក្សីសំខាន់ៗមួយចំនួន ដែលបានកំណត់អត្តសញ្ញាណ ដោយអង្គការ BirdLife ពិភពលោក។ គេបានចាត់ទុកថា

មានប្រភេទពូជកំរ និងពូជកំពុងរងគ្រោះថ្នាក់ជាច្រើនរស់នៅក្នុង LMDFE រួមមាន ខ្លា ដំរី ខ្ទីង ទន្សោង ក្របីព្រៃ រមាំង ខ្លាលឿងមាស ខ្លាត្រី ខ្លាឃ្មុំខ្មៅ និងទោច ក៏ដូចជាពូជបក្សីជាច្រើនរួមមាន ក្រៀល និងពូជត្មាតផ្សេងៗជាច្រើនទៀត។

ការសិក្សាពីសត្វព្រៃដែលធ្វើឡើងដោយ KCC ក្នុងឆ្នាំ ២០០៨ នៅរដូវប្រាំង បានរកឃើញថា ជាទូទៅមានទិន្នន័យដែលមិនពិតប្រាកដដែលមានទាក់ទងទៅនឹងការស្ទង់មតិ/ការស្រាវជ្រាវនៅក្នុងតំបន់គំរោង។ ការសិក្សាបានរកឃើញពីការអង្កេតដោយផ្ទាល់នៅទីវាលរបស់ KCC និង តាមរយៈការពិភាក្សាជាមួយអ្នកភូមិចាស់ៗ និងអ្នកបរបាញ់នៅក្នុងតំបន់ថា វត្តមានរបស់សត្វធំៗ ដូចជាទន្សោង ខ្ទីង ដំរីអាស៊ី ខ្លាឃ្មុំ ហើយអំបូរថនិកសត្វថ្នាក់ខ្ពស់ ឃើញមានដោយកំរ ប៉ុន្តែសត្វតូចៗដូចជាជ្រូកព្រៃ ឈ្លូស និងល្មូនដូចជាអន្សង និងអណ្តើក តែងតែប្រទះឃើញជាញឹកញាប់។

មានជម្រកត្រីធម្មជាតិយ៉ាងសំខាន់នៅក្នុងទន្លេសេសាន និងទន្លេស្រែពក ទោះបីជាចំនួនត្រីកំពុងបានថយចុះនៅប៉ុន្មានឆ្នាំថ្មីៗនេះដោយសារសកម្មភាពអភិវឌ្ឍន៍នានា កំនើនប្រជាជន និងប្រភេទឧបករណ៍នេសាទដែលបានប្រើប្រាស់។ មានពូជត្រីច្រើនជាង ១០០ ពូជ មានវត្តមាននៅក្នុងទន្លេទាំងពីរ ដែលក្នុងនោះពូជត្រីប្រហែល ៦៦% ធ្វើការបំលាស់ទី។ គេបានកត់សំគាល់ថា ពូជត្រីមួយចំនួន បានធ្វើការផ្លាស់ទីជាទៀងទាត់ ពីបឹងទន្លេសាប និងទន្លេមេគង្គ មកកាន់ទន្លេសេសាន និងទន្លេស្រែពក និងចេញពីទន្លេទាំងពីរនេះត្រឡប់ទៅវិញ ហើយពូជត្រីមួយចំនួនទៀតមកពីកន្លែងយ៉ាងឆ្ងាយនៃដីសណ្តទន្លេមេគង្គ។

### c) ការអភិវឌ្ឍន៍សេដ្ឋកិច្ច និង ធនធានសង្គម

ស្រុកសេសាន ដែលជាតំបន់មូលដ្ឋានរបស់គំរោង រួមមានឃុំចំនួនបួន ដែលមានប្រជាជនសរុប ១២.៩៦១ នាក់។ នៅខ្សែទឹកលើនៃតំបន់គំរោង មានភូមិជាច្រើនស្ថិតនៅតាមបណ្តោយទន្លេសេសាន និង ទន្លេស្រែពក (ដែលភាគច្រើននៅតាមទន្លេសេសាន) ដែលមានចំនួនប្រជាជនសរុបប្រហែល ៤០.០០០ នាក់ ។ នៅខ្សែទឹកខាងក្រោមនៃតំបន់គំរោង មានភូមិជាច្រើន និង ទីរួមខេត្តស្ទឹងត្រែងដែលមានប្រជាជនសរុបប្រហែល ៤៥.០០០ នាក់។

ការនេសាទ និង ការដាំដុះស្រូវគឺជាសកម្មភាពចំបងរបស់អ្នកភូមិដែលរស់នៅតាមដងទន្លេ។ ពួកគេក៏ដាំដុះប្រភេទដំណាំផ្សេងៗទៀតជាច្រើនផងដែរ។ តំបន់កសិកម្មរបស់ស្រុកសេសាន (ស្រុកដែលភាគច្រើននៃអាងស្តុកទឹកតាំងនៅ) មានប្រហែល ៥១៦០ ហត។

ដោយប្រើប្រាស់តួរលេខចេញពីការសិក្សាត្រីដែលធ្វើឡើងដោយ KCC នៅក្នុងឆ្នាំ ២០០៨ រដូវប្រាំង គេបានប៉ាន់ប្រមាណថាចំនួនត្រីដែលបានចាប់នៅក្នុងទន្លេសេសាន និង ទន្លេស្រែពក (នៅក្នុងប្រទេសកម្ពុជា) មានបរិមាណសរុបប្រហែល ៦៤៧ តោនក្នុងមួយឆ្នាំ។



Draft

ភូមិដែលនៅតាមដងទន្លេសេសាន និង ទន្លេស្រែពកមានជនជាតិផ្សេងៗជាច្រើនដូចជា ចារ៉ាយ គ្រឹង ទំពូន ភ្នង ព្រៅ កញ្ជាក់ ឡាវ ហើយហេដ្ឋារចនាសម្ព័ន្ធនៅមានកំរិតកំណត់នៅឡើយ ដូចជាសាលារៀន មណ្ឌលសុខភាព និង ផ្លូវថ្នល់ជាដើម ។ ប្រជាជានជាច្រើនធ្វើដំណើរដោយទូកតូចៗឡើងចុះតាមទន្លេ។ មានការងារតិចតួច ហើយប្រជាជនភាគច្រើនរស់នៅតាមការចិញ្ចឹមជីវិតដោយសមាជីវ៉ា។ មានតំបន់ទេសចរណ៍ពីរកន្លែងនៅជិតតំបន់គំរោង គួរអោយកត់សំគាល់ ដូចជាទឹកធ្លាប្ធជូរដែលស្ថិតនៅពីរបី គីឡូម៉ែត្រខាងក្រោមទីតាំងទំនប់។ មិនមានតំបន់ប្រវត្តិសាស្ត្រ ឬ វប្បធមិដែលបានស្គាល់នៅក្នុងតំបន់ គំរោងទេ ។

មានព្រៃ និង ដីសម្បទានជាច្រើនដែលបានអនុម័តរួច ស្ថិតនៅក្នុងតំបន់គំរោង ហើយ ៣១%នៃផ្ទៃអាងដែលបានស្នើឡើងស្ថិតនៅក្នុងតំបន់សម្បទានដែលបានអនុម័តរួចរាល់ទាំងនោះ ។

## ៥. ផលប៉ះពាល់ និង វិធានការណ៍បន្ធូរបន្ថយ

### *ក) ផលប៉ះពាល់ទៅលើធនធានបរិស្ថាន*

ផលប៉ះពាល់ជាសំខាន់គឺការបាត់បង់ទីជំរករបស់ពពួលសត្វ និងរុក្ខជាតិ ដែលផ្ទុកទៅដោយពូជកំរ និងពូជកំពង់រងគ្រោះមួយចំនួន ដែលជាលទ្ធផលរួមគ្នានៃផ្ទៃអាងដែលជន់លិច តំបន់តាំងទីលំនៅសារជាថ្មី និងការធ្វើផ្លូវវាងផ្លូវជាតិលេខ ៧៨ ។ ផ្ទៃដីព្រៃប្រហែល ៣០០០០ហត នឹងត្រូវបំផ្លាញ ដែលប៉ះពាល់យ៉ាងខ្លាំងដល់ពពួកសត្វព្រៃ ក៏ដូចជាប្រភេទសត្វកំពុងរងគ្រោះនៅក្នុងតំបន់ទាំងនេះ ។

ផលប៉ះពាល់ទៅលើត្រីនឹងមានលក្ខណៈធ្ងន់ធ្ងរដោយសារពូជត្រីជាច្រើនជាពូជដែលធ្វើការផ្លាស់ទី (ប្រហែល ៦៦%) ហើយផ្លូវធ្វើដំណើររបស់វានឹងត្រូវកាត់ផ្តាច់ដោយទំនប់។ ហេតុដូចនេះវា នឹងមានហេតុប៉ះពាល់ដល់ធនធានត្រីនៅខ្សែទឹកក្រោមនៃទំនប់ ដូចជានៅទន្លេមេគង្គ និងនៅបឹងទន្លេសាបផងដែរ។ ដោយសារឧបសគ្គនៃទំនប់នឹងបណ្តាលអោយពូជត្រីមួយចំនួនបាត់បង់ ហើយធ្វើអោយថយចុះយ៉ាងខ្លាំងដល់ទិន្នផលត្រីប្រចាំឆ្នាំ ។

ទោះបីជាមានដី/ព្រៃសម្បទានរួចជាស្រេចដែលគ្របដណ្តប់តំបន់ទាំងនេះហើយក៏ដោយ ក៏ហេតុប៉ះពាល់នឹងនៅតែមានគួរអោយកត់សំគាល់ ដោយសារថាដី នឹងតំបន់ទន្លេយ៉ាងធំធេងទាំងនោះនឹងត្រូវបំផ្លិចបំផ្លាញ។ នឹងមានហេតុប៉ះពាល់ខ្លាំងទៅលើព្រៃឈើ និងជំរកសត្វព្រៃ ដោយសារការបាត់បង់ព្រៃឈើរាប់សិបពាន់ហិចតា ដោយសកម្មភាពគំរោង ។

គុណភាព និងបរិមាណទឹករបស់ទន្លេសេសាន នៅខ្សែទឹកក្រោមនៃទីតាំងទំនប់នឹងផ្លាស់ប្តូរផងដែរដែលប៉ះពាល់ដល់ទាំងប្រជាជន ត្រី និង សត្វព្រៃ។ រំហូរទឹកក្នុងទន្លេនឹងធ្វើអោយបាត់បង់ដល់ការប្រែប្រួលកំពស់ទឹកតាមធម្មជាតិនូវរដូវប្រាំង និងរដូវវស្សា ហើយគុណភាពទឹកទំនងជានឹងត្រូវថមថយ ជាពិសេសក្នុងរយៈពេល សាងសង់ និងប៉ុន្មានឆ្នាំដំបូងនៃប្រតិបត្តិការ ដោយសារកករដី និងការបំបែកធាតុសារធាតុសរីរាង្គនៅក្នុងទឹក។ ការផ្គត់ផ្គង់ទឹក

Draft

នៅខេត្តស្ទឹងត្រែងបានមកពីទន្លេសេកុង ដែលប្រសព្វគ្នាជាមួយទន្លេសេសានផងដែរ នៅចំងាយ ១០គម ខាងលើទីរួមខេត្ត ហើយគុណភាពទឹកនៃទឹកទន្លេអាចប៉ះពាល់ដល់ការផ្គត់ផ្គង់ទឹករបស់ទីរួមខេត្ត ក៏ដូចជាការផ្គត់ផ្គង់ទឹកសំរាប់ភូមិដែលមានទីតាំងនៅតាមដងទន្លេសេសានខ្សែទឹកខាងក្រោមរបស់ទំនប់ ។ សំណើកដែលបណ្តាលអោយមានការកើនឡើងកំទេចកំណ និង កាកសំណល់ដែលបណ្តាលអោយកខ្វក់ទឹក អាចប៉ះពាល់ដល់គុណភាពទឹក ជាពិសេសក្នុងកំឡុងពេលដំណាក់កាលសាងសង់ ។

ទីតាំងទំនប់លាតសន្ធឹងនៅក្នុងតំបន់ដែលមានស្នាមប្រេះភូគព្ភសាស្រ្ត ហើយមានកំណត់ត្រាពីការរញ្ជួយដីដែលបានកើតឡើងនៅក្នុងតំបន់នេះមានរង្វាស់ ៥.២ Richter នៅឆ្នាំ ១៩៧៨។ នោះមានន័យថា តំបន់នេះអាចនឹងមានការរញ្ជួយដី ដែលអាចបង្កជាហេតុប៉ះពាល់នៅលើទំនប់ ឬ រចនាសម្ព័ន្ធដែលទាក់ទងប្រសិនបើវាកើតឡើង ។

គំរោងនឹងបន្ថែមនូវបណ្តុំហេតុប៉ះពាល់ពីទំនប់នៅក្នុងតំបន់រងទឹកភ្លៀងនៃទន្លេសេសាន និងទន្លេស្រែពក មានជាអាទិ៍ ហេតុប៉ះពាល់ លើគុណភាពនិងបរិមាណទឹក លើជីវភាពនិងសុខមាលភាពប្រជាជន និងលើសត្វព្រៃ ជាពិសេសប៉ះពាល់ទៅលើត្រី និងភាវរសក្នុងទឹក ។

*ខ) ផលប៉ះពាល់ទៅលើការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ច*

Draft

ហេតុប៉ះពាល់ជាច្រើនដែលបានគូសបង្ហាញខាងលើ នឹងបង្កផលប៉ះពាល់ដល់បរិស្ថានផង និងសង្គមដោយផ្ទាល់ផង ។ គំរោងវារីអគ្គិសនីនេះ នឹងបង្កហេតុប៉ះពាល់លើជីវភាពរស់នៅរបស់ប្រជាជននៅក្នុង និងនៅជុំវិញតំបន់គំរោង ជាពិសេសតាមរយៈការបាត់បង់ដី ការបាត់បង់ត្រី បញ្ហាគុណភាព និង បរិមាណទឹក និង ផ្លូវថ្នល់ ។

អាងស្តុកទឹកនឹងបណ្តាលអោយមានការផ្លាស់ប្តូរទីលំនៅរបស់ប្រជាជនចំនួន ១០៥២ គ្រួសារ ដែលមានប្រជាជនសរុបចំនួន ៤៧៥៤ នាក់ (ទិន្នន័យឆ្នាំ ២០០៧) ឬ ១៥៧៩ គ្រួសារ ដែលមានប្រជាជនសរុបចំនួន ៦៥០៧ នាក់ (ទិន្នន័យប៉ាន់ស្មានឆ្នាំ ២០១១) ពីប្រាំពីរភូមិនៅក្នុងឃុំចំនួនបួនរបស់ស្រុកពសានទៅកាន់តំបន់តាំងទីលំនៅសារជាថ្មី ។

គេបានដឹងថា តំបន់ស្នើសុំសំរាប់ការ តាំងទីលំនៅសារជាថ្មី គឺតាំងនៅលើដី និងព្រៃសម្បទាន ដែលមានការអនុម័តសំរេចរួចហើយ ដែលជាឧបសគ្គមួយគួរពិចារណានាពេលបច្ចុប្បន្ន និងទៅអនាគត ។

គេបានកំណត់សំគាល់ឃើញថា ត្រីជាប្រភពអាហារចិញ្ចឹមជីវិតយ៉ាងសំខាន់ របស់អ្នកភូមិដែលរស់នៅតាមដងទន្លេសេសាន និង ទន្លេស្រែពក (ប្រហែល ៤០០០០នាក់) ។ គេបាន ពិចារណាថាហេតុប៉ះពាល់សង្គមសេដ្ឋកិច្ចចេញពីការបាត់បង់ត្រី គឺជាហេតុប៉ះពាល់យ៉ាងធំមួយរបស់ទំនប់ ។

ផ្ទៃដីកសិកម្មដែលមានស្រាប់របស់ស្រុកសេសានគឺ ៥២២០ ហត ។ ការបាត់បង់ដីកសិកម្មបណ្តាលមកពីអាងស្តុកទឹកគឺ ១២១៦.៨ ហត ឬ ២៤% នៃផ្ទៃដីកសិកម្មសរុបនៅក្នុងស្រុកសេសាន ។ ទោះបីជាដីកសិកម្មត្រូវបានស្នើ

ជំនួសនៅក្នុងតំបន់តាំងទីលំនៅសារជាថ្មីក៏ដោយ (តំរូវអោយមានការកាប់ឆ្ការដីព្រៃ) ក៏ការបាត់បង់ដីកសិកម្ម មានផលប៉ះពាល់ដល់សេដ្ឋកិច្ច សង្គម និង បរិស្ថាន ជាពិសេសក្នុងន័យនៃការបាត់បង់ប្រាក់ចំណូល ជីវភាព និង តំបន់ដីព្រៃឈើ ។

គំរោងអាចមានហេតុប៉ះពាល់ដល់ការផ្គត់ផ្គង់ទឹក និងសុខភាពប្រជាជនក្នុងមូលដ្ឋាន ដោយសារគុណភាពមិនល្អ អំឡុងពេលសាងសង់ និងប៉ុន្មានឆ្នាំដំបូងនៃប្រតិបត្តិការទំនប់ ។

ទំនប់នឹងបង្ខាំងប្រជាជនមិនអោយធ្វើដំណើរតាមទូកឆ្លងកាត់ទីតាំងទំនប់ នៅពេលដែលទំនប់ត្រូវបានសាងសង់។ ប្រជាជនមួយចំនួននៅតែធ្វើដំណើរតាមទូករវាងភូមិខាងលើ និង ខាងក្រោមទីតាំងទំនប់ ហើយប្រជាជនមួយចំនួនទៀតនៅតែធ្វើដំណើរយ៉ាងឆ្ងាយទៅកាន់ក្រុងស្ទឹងត្រែង។

ក្នុងកំឡុងពេលគំរោងសាងសង់ នឹងមានប្រើប្រាស់កំលាំងពលកម្មប្រជាជនយ៉ាងច្រើនដល់ទៅ ៣០០០ នាក់ ដែលនឹងត្រូវរស់នៅក្នុងជំរុំការដ្ឋានសាងសង់។ ប្រសិនបើកម្មករគំរោងមិនមានការគ្រប់គ្រងបានត្រឹមត្រូវទេ វានឹងមានហេតុប៉ះពាល់ដល់ផ្នែកសង្គមជាពិសេសទៅលើវប្បធម៌មូលដ្ឋាន និង ភូមិដែលនៅក្បែរគ្នាក្នុងន័យឥទ្ធិពលសង្គមទៅវិញទៅមក និង ឥទ្ធិពលពីខាងក្រៅដូចជាការប្រើប្រាស់ថ្នាំញៀនជាដើម ។

ការធ្វើចរាចរក៏អាចបណ្តាលអោយមានហេតុប៉ះពាល់ដល់សង្គមផងដែរ ជាពិសេសផ្នែកសុខភាព តាមរយៈគ្រោះថ្នាក់ចរាចរ ដែលទាក់ទងទៅនឹងបុគ្គលិកគំរោង ជាមួយប្រជាជនមូលដ្ឋាន ។ ការកើនឡើងធូលីដីដែលបង្កបញ្ហាសុភាពផ្លូវដង្ហើមដល់ប្រជាជនដែលរស់នៅជិតផ្លូវថ្នល់ ជាពិសេសអំឡុងពេលសាងសង់។

ទឹកធ្លាក់ ឬជ្រោះមួយចំនួន ដែលស្ថិតនៅមិនឆ្ងាយផ្នែកខាងក្រោមទីតាំងទំនប់ ដែលជាកន្លែងទាក់ទាញភ្ញៀវទេសចរណ៍ ជាពិសេសភ្ញៀវក្នុងស្រុក។ ការប្រែប្រួលលំហូរទឹកនៅក្នុងទន្លេអាចធ្វើអោយតំបន់នេះបន្ថយការទាក់ទាញទេសចរណ៍ និង អាចមានគ្រោះថ្នាក់ដល់អ្នកលេងទឹក នៅពេលទំនប់បើកបញ្ចេញទឹក។

សកម្មភាពសាងសង់គំរោង នឹងមានហានិភ័យ ជាមួយនឹងគ្រាប់បែកបូមប៊ី ឬយោធភ័ណ្ឌមិនទាន់ផ្ទុះ ដែលបន្សល់ពីសម័យសង្គ្រាមនាអតិតកាល។

## ៦. វិធានការណ៍កាត់បន្ថយសំខាន់ៗ

ម្ចាស់គំរោងត្រូវអនុវត្តនូវវិធានការណ៍បន្ធូរបន្ថយចំពោះ ហេតុប៉ះពាល់អវិជ្ជមានលើបរិស្ថាន និងសង្គមដូចតទៅ :

- បន្ថយផ្ទៃដីដែលរងផលប៉ះពាល់ ដោយសារអាងស្តុកទឹក និងតំបន់តាំងទីលំនៅសារជាថ្មី តាមរយៈការកាត់បន្ថយកំពស់ទំនប់អោយបានច្រើនតាមដែលអាចធ្វើទៅបាន។



Draft

- តំបន់តាំងទីលំនៅសារជាថ្មី និងផ្លូវវាងផ្លូវជាតិលេខ ៧៨ ត្រូវមានទីតាំងនៅក្នុងតំបន់ដែលមានហេតុប៉ះពាល់បរិស្ថានតិចតួចបំផុត ហើយថវិកាសាងសង់ជាបន្ទុករបស់ក្រុមហ៊ុនសាងសង់ទំនប់ ។
- ការដាំឈើជាសំណង និង ការផ្តល់ការផ្តួចផ្តើមពីការអភិរក្សសត្វព្រៃ និង ព្រៃឈើ នៅក្នុងតំបន់ដែលនឹងត្រូវធ្វើឡើងដោយក្រុមហ៊ុនទំនប់ ។
- ការតាំងទីលំនៅសារជាថ្មី ធ្វើឡើងដោយអនុឡោមទៅតាម ផែនការគ្រប់គ្រងការតាំងទីលំនៅឡើងវិញ ហើយ ដី និងហេដ្ឋារចនាសម្ព័ន្ធដែលបានផ្តល់អោយ ត្រូវតែដូចទៅនឹងដី និង ហេដ្ឋារចនាសម្ព័ន្ធ ដែលអ្នកភូមិមានពីមុន ឬប្រសើរជាងមុន។ ការទូទាត់សងនឹងត្រូវផ្តល់ ដោយមានការចចារជាមួយអ្នកភូមិដែលរងផលប៉ះពាល់ និងយោងតាមទំរង់ផែនការតាំងលំនៅសារជាថ្មី ដែលបានអនុម័តដោយ IRC/MEF និង អន្តរក្រសួង ។
- មូលនិធិបរិស្ថាន នឹងត្រូវបង់ជូនរាជរដ្ឋាភិបាលកម្ពុជា សំរាប់ហេតុប៉ះពាល់មិនអាចប៉ាន់ស្មានបាន និងផែនការគ្រប់គ្រងបរិស្ថាន រាប់បញ្ចូលទាំងការដាំឈើឡើងវិញ ឬកម្មវិធីការពារព្រៃឈើ និង អភិរក្សសត្វព្រៃនៅក្នុងតំបន់ ។
- កិច្ចព្រមព្រៀងរវាងម្ចាស់គំរោង និង ម្ចាស់ដីនិងព្រៃសម្បទាន ត្រូវតែសំរេចបានការយល់ព្រមលើផ្ទៃដី ឬផ្ទៃព្រៃ សម្បទាន ដែលនឹងត្រូវជន់លិចដោយអាងស្តុកទឹក មុនទំនប់ត្រូវបានសាងសង់ ។
- ទំនប់ត្រូវតែរៀបចំប្លង់ និង សាងសង់អោយធន់ទ្រាំបានទៅនឹងព្រឹត្តិការណ៍រញ្ជួយដីក្នុងតំបន់ ។
- បោសសំអាតសំណល់គ្រាប់បែក និងយោធភ័ណ្ឌមិនទាន់ផ្ទុះ នៅទីតាំងសាងសង់ តំបន់តាំងលំនៅសារជាថ្មី និងការដ្ឋានយកដី ឬថ្ម នឹងត្រូវធ្វើ ដើម្បីជៀសវាងហានិភ័យដល់សុខភាព ។
- រុករក និងសំអាតជាតិគីមីពុល ។
- ធ្វើការជាមួយអន្តរក្រសួង និងអាជ្ញាធរមូលដ្ឋាន ដើម្បីបង្កើតផែនការមួយ សំរាប់ប្រមូលយកឈើមានតំលៃពីព្រៃដែលត្រូវលិចក្នុងអាងស្តុក សំរាប់ប្រើក្នុងគោលបំណងផ្សេងៗ មុននឹងពន្លិចទឹក ។
- ត្រួតពិនិត្យពីសំណឹក និងការរងកករត្រឹមត្រូវ និង ការអនុវត្តការគ្រប់គ្រងកាកសំណល់ គួរត្រូវអនុវត្តជាពិសេសក្នុងដំណាក់កាលសាងសង់ ។
- ត្រួតពិនិត្យគុណភាព និង បរិមាណទឹកដែលនឹងត្រូវធ្វើយ៉ាងទៀងទាត់ នៅខាងលើ និងខាងក្រោមទីតាំងទំនប់ ហើយការខូចខាតគុណភាពទឹក ត្រូវតែធ្វើការកែលំអរជាបន្ទាន់ ។
- ការខូចខាតផ្លូវដែលបង្កដោយចរាចរណ៍របស់គំរោង នឹងត្រូវតែធ្វើការជួសជុលជាបន្ទាន់ ហើយតំលៃជួសជុលជាបន្ទុករបស់ម្ចាស់គំរោង ។
- ម្ចាស់គំរោងនឹងរៀបចំបទបញ្ជាមួយសំរាប់កម្មករគំរោង អោយគោរព វប្បធម៌ និងប្រពៃណីរបស់សហគមន៍ក្នុងមូលដ្ឋាន ។



Draft

- ម្ចាស់គំរោងនឹងត្រូវរៀបចំសញ្ញាសំគាល់សំរាប់ដាក់គ្រប់ផ្លូវ សញ្ញាសំគាល់ត្រូវមានបញ្ជាក់ផងដែរ ពីបញ្ហាប្រើប្រាស់ផ្លូវផ្ទាល់ទៅតាមច្បាប់ផ្លូវទាំងអស់ ដែលត្រូវគោរពតាមយ៉ាងខ្ជាប់ខ្ជួន បទបញ្ជាចរាចរណ៍ ជាពិសេសការដាក់កំណត់ល្បឿន។
- ទីកន្លែងសុខភាពគួរត្រូវផ្តល់អោយនៅតំបន់គំរោងសំរាប់កម្មករគំរោងដើម្បីជួយមិនអោយមានការរាតត្បាតជំងឺជាពិសេសចូលទៅដល់សហគមន៍មូលដ្ឋាន។
- គ្រប់អោយបានត្រឹមត្រូវ រាល់សំណល់ពីការដ្ឋានសាងសង់ និងសំណល់មនុស្ស ពីជំរុំកម្មករ ។
- ផ្តល់កម្មវិធីទ្រទ្រង់កសិកម្ម ដល់អ្នកភូមិដែលរស់នៅតាមដងទន្លេ សេសាន និងស្រែពក ក្នុងខេត្តរតនគីរី និងមណ្ឌលគីរី ដូចជា (១) ការចិញ្ចឹមសត្វៈ គោ ក្របី មាន់ ទា ជ្រូក និងសត្វពាហនៈ ផ្សេងទៀត។ (២) ការធ្វើប្រពលវប្បកម្មលើដំណាំស្រូវ បន្លែ និងដំណាំដទៃទៀត ។

## ៧_ ការពិគ្រោះយោបល់ជាសាធារណៈ

Draft

អំឡុងពេលនៃការរៀបចំរបាយការណ៍ EIA ការពិគ្រោះយោបល់ជាសាធារណៈត្រូវបានពិភាក្សាពីគំរោងទំនប់ស្នើសុំ ទៅលើចំនុចសំខាន់ៗដែលនឹងអាច កើតចេញពីការអនុវត្តន៍គំរោង។ ការប្រជុំលើកទីមួយត្រូវបានធ្វើឡើងតាមរយៈការជួបប្រជុំជាមួយសហគមន៍ដែលនឹងរងផលប៉ះពាល់ផ្ទាល់ដោយសារគំរោង ។ កិច្ចប្រជុំលើកទីមួយនេះបានរៀបចំដោយក្រុមសិក្សារបស់ KCC នៅដើមខែកុម្ភៈ ២០០៨ នៅក្នុងឃុំចំនួន ៥ ដែលនឹងរងផលប៉ះពាល់ផ្ទាល់ដោយគំរោង (ឃុំ ភ្លុក ក្បាលរមាស ស្រែគរ តាឡាត និង ឃុំស្រែអង្រ្កង) ផ្អែកលើប្លង់រចនាគំរោងដំបូង។ ការប្រជុំបានបង្ហាញ និងផ្តល់ដល់សហគមន៍មូលដ្ឋាននូវពត៌មានអំពីគំរោង និង ការរំលឹកពីបញ្ហាបរិស្ថាន ដែលអាចកើតឡើងជាលទ្ធផលរបស់គំរោងស្នើសុំ ។ បន្ទាប់ពីបានបង្ហាញពត៌មាន អ្នកភូមិដែលបានចូលរួមប្រជុំ ត្រូវបានចោទសួរជាសំនួរអំពីគំនិតចំណាប់អារម្មណ៍លើគំរោងស្នើសុំអភិវឌ្ឍន៍នេះ ហើយជាលទ្ធផលគឺ ៨៥% បាននិយាយថា ពួកគេមិនយល់ព្រមទៅនឹងគំរោងស្នើសុំនេះទេ។

ការពិគ្រោះយោបល់លើកទីមួយដំណាក់កាលទីពីរត្រូវបានធ្វើដោយ PECC1 ក្នុងកំឡុងខែមេសា ២០០៨ ហើយការប្រជុំនេះ សំដៅចំពោះប្រជាជនដែលរងផលប៉ះពាល់ដោយផ្ទាល់ដោយគំរោងទំនប់ និង ចាំបាច់នឹងត្រូវផ្លាស់ប្តូរទីលំនៅ ។ មុនពេលប្រជុំដំណាក់កាលទីពីរនេះឃុំមួយចំនួន និងប្រធានភូមិ ព្រមទាំងតំណាងមន្ទីរខេត្តមួយចំនួនបានចុះធ្វើទស្សនៈកិច្ចនៅតំបន់តាំងទីលំនៅសារជាថ្មីក្នុងប្រទេសវៀតណាម ដែលត្រូវបានស្ថាបនាដោយសារគំរោងអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីយ៉ាលី (Yali) នៅលើទន្លេសេសានខាងលើ ។ លើសពីនេះទៀត គ្រួសារដែលរងផលប៉ះពាល់ ត្រូវបានជំរាបជូនពីផ្ទៃដីដែលនឹងត្រូវបានបាត់បង់ដោយសារគំរោង ហើយត្រូវបានផ្តល់ពត៌មានអំពីវិធានការណ៍សំណងដែលបានស្នើឡើងសំរាប់ការតាំងទីលំនៅសារជាថ្មីរបស់ពួកគេ ។ បន្ទាប់ពីបានធ្វើការពិគ្រោះយោបល់ទាំងនេះរួចមក ការចុះស្ទង់មតិមួយត្រូវបានធ្វើឡើងដោយ PECC1 អំពីគ្រួសារដែលរងផលប៉ះពាល់

ថាតើប្រជាជនដែលរងផលប៉ះពាល់នៅពេលបច្ចុប្បន្នយល់ព្រម ឬ មិនយល់ព្រមជាមួយគំរោង ។ PECC1 រាយការណ៍ថា មាន ៩៤% នៃប្រជាជនដែលរងផលប៉ះពាល់ទាំងអស់បានយល់ព្រមជាមួយគំរោង។

ការពិគ្រោះយោបល់លើកទីបី គឺការប្រជុំជាមួយនឹងអ្នករួមចំណែកដែលបានប្រារព្ធឡើងនៅក្នុងទីរួមខេត្តស្ទឹងត្រែង នៅដើមខែ ឧសភា ២០០៨ ។ អ្នករួមចំណែកដែលបានអញ្ជើញអោយចូលរួម រួមមានតំណាងសហគមន៍ដែលរងផលប៉ះពាល់នៅក្នុងខេត្តស្ទឹងត្រែង មន្ទីរពាក់ព័ន្ធទាំងអស់របស់ខេត្តស្ទឹងត្រែង អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ផ្នែកឯកជនផ្សេងៗដែលចាប់អារម្មណ៍ និង តំណាងក្រសួងបរិស្ថាន និង ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល។ អភិបាល និងអភិបាលរងខេត្តស្ទឹងត្រែងក៏បានចូលរួមផងដែរ ។ បទបង្ហាញជា Powerpoint នៅក្នុងការប្រជុំនេះត្រូវបានធ្វើឡើងដោយ KCC និង PECC1 ដែលបានផ្តល់យ៉ាងលំអិតពីប្លង់វិស្វកម្ម និង ពត៌មានសិក្សាបរិស្ថាន ។ សំនួរ/មតិយោបល់មួយចំនួនត្រូវបានសួរដោយ អ្នកចូលរួមពីរបីនាក់ប៉ុណ្ណោះ ហើយ PECC1 បានបញ្ជាក់បង្ហាញថានឹងត្រូវយកគិតគូរពិចារណានៅក្នុងការសិក្សារៀបចំរបាយការណ៍ EIA ។

ការពិគ្រោះយោបលមួយចំនួនទៀតត្រូវបានអនុវត្តនៅកំឡុងពេលស្ទង់មតិពីសង្គម និង សត្វព្រៃដែលបានធ្វើឡើងដោយ KCC នៅខែកុម្ភៈ ដល់ខែមេសា ឆ្នាំ ២០០៨ ជាមួយ អជ្ញាធរថ្នាក់មូលដ្ឋាន មេឃុំ និង NGOs មួយចំនួន។

## ៨. សន្និដ្ឋាន

ទោះបីជាគំរោងរោចក្រវារីអគ្គិសនីសេសាន ២ នឹងផលិតនូវបរិមាណថាមពលយ៉ាងច្រើន (១៩៥៣.៩ GWh ក្នុងមួយឆ្នាំ) សំរាប់ខេត្តភាគឦសានក្នុងប្រទេសកម្ពុជា និង នាំចេញទៅកាន់ប្រទេសវៀតណាម (ប្រសិននៅសល់ពីតំរូវការក្នុងប្រទេសកម្ពុជា) ។ ប្រភពថាមពលទាំងនេះនឹងជាកំលាំងយន្តការរុញច្រានការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិនៃប្រទេសកម្ពុជា ។

ទោះបីយ៉ាងណាក៏ដោយ ក៏គំរោងនេះនឹងបង្កអោយមានហេតុប៉ះពាល់សំខាន់ៗដល់សង្គម និងបរិស្ថាន មួយចំនួន ពោលគឺ ការបាត់បង់ព្រៃឈើ ការថយចុះនូវទិន្នផលត្រីធម្មជាតិក្នុងទន្លេសេសាន និងទន្លេស្រែពក ព្រមទាំងក្នុងមេគង្គខ្សែទឹកខាងក្រោម និងបឹងទន្លេសាប ហើយនិងការតាំងទីលំនៅសារជាថ្មីចំនួន ១៥៧៩ គ្រួសារ។

វិធានការណ៍កាត់បន្ថយដ៏មានប្រសិទ្ធភាព នឹងបន្ធូរបន្ថយហេតុប៉ះពាល់អវិជ្ជមាន ដែលបង្កដោយគំរោងបានយ៉ាងច្រើន។

របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ជាឯកសារដ៏មានសារៈសំខាន់ជួយដល់អ្នកអនុម័តសំរេចក្នុងដំណើការអនុញ្ញាតយល់ព្រម ដើម្បីថ្លឹងថ្លែងផលចំណេញសេដ្ឋកិច្ច និងការបាត់បង់បរិស្ថាន ។

Draft

Draft